PPCBank

# របាយការណ៍ប្រចាំត្រីមាសទី៣

(ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---:|---:|
| ទ្រព្យសកម្មសរុប | ៤,២៥៥,៤៣៩ | ៣,៨១៥,៣៦៦ |
| បំណុលសរុប | ៣,៦៣៧,៧៦៣ | ៣,២៥០,៩៨០ |
| មូលធនសរុប | ៦១៧,៦៧៧ | ៥៦៤,៣៨៥ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី៣ ឆ្នាំ២០២០** | **ត្រីមាសទី៣ ឆ្នាំ២០១៩*** |
| ចំណូលសរុប | ៧៤,៧៨៤ | ៦៣,៤៨១ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ២១,៣១៨ | ២០,០២១ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ១៦,៨៧៥ | ១៤,៩៥០ |
| លទ្ធផលម្អិតក្នុងការិយបរិច្ឆេទ | ១៧,៣៥៥ | ១៦,៤៥៥ |
| **អនុបាតហិរញ្ញវត្ថុ(%)** | **ត្រីមាសទី៣ ឆ្នាំ២០២០** | **ឆ្នាំ២០១៩** |
| អនុបាតសោធនភាព ❶ | ១៧.៤៦ | ១៩.០៩ |
| អនុបាតបំណុលធៀបនឹងមូលធន | ៥៨៨.៩៤ | ៥៧៦.០២ |
| អនុបាតសន្ទនីយភាព ❶ | ១៣៦.១៤ | ១៤៩.២៣ |
| អនុបាតឥណទានមិនដំណើរការ ● | ១.១១ | ១.២១ |
| អនុបាតបញ្ញើធៀបនឹងឥណទាន | ៨៤.១៧ | ៨៦.៥៨ |
| **អនុបាតផលចំណេញ(%)** | **ត្រីមាសទី៣ ឆ្នាំ២០២០** | **ត្រីមាសទី៣ ឆ្នាំ២០១៩*** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) | ១.៦២ | ១.៨៣ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) | ១១.១៨ | ១១.៧៧ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៦៧៩.៨៤ | ៧៩០.០១ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | គ្មាន | គ្មាន |

សំគាល់ : * ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ មិនត្រូវបានធ្វើសវនកម្ម ឬត្រួតពិនិត្យទេ

❶ : អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយ ធនាគារជាតិនៃកម្ពុជា

❷: ឥណទានមិនដំណើរការ អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយ ធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

សមាជិក



**HEO, Ryeon**

សមាជិក



**PARK, Chong Tae**

អភិបាលឯករាជ្យ



**LEE, Myunsang**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាលខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការបង្ហាញពីលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញពាណិជ្ជ ម.ក ក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ដោយអនុវត្តតាមតម្រូវការរបស់គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក)។

ដូចដែលយើងទាំងអស់គ្នាបានជ្រាបរួចមកហើយ អំពីការរីករាលតត្បាតនៃជម្ងឺវីរុសកូរ៉ូណាថ្មី (COVID-19) ដែលបានរីករាតត្បាតជាសកលយ៉ាងឆាប់រហ័ស ឆ្លងមនុស្សរាប់លាននាក់ និងធ្វើឲ្យសកម្មភាពសេដ្ឋកិច្ចនៅត្រឹង ក៏ដូចជាបណ្តាប្រទេសជាច្រើនបានដាក់កម្រិតយ៉ាងតឹងរឹងទៅលើការបំលាស់ទី ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសនេះ។ ការរីករាតត្បាតជាសកលនៃវីរុសនេះ បានធ្វើឲ្យសាលារៀនត្រូវបានផ្អាក ភាពក្រីក្រ និងហានិភ័យរបស់កុមារកាន់តែធ្ងន់ធ្ងរ ដែលធ្វើឲ្យប៉ះពាល់ដល់ឱកាសអភិវឌ្ឍន៍សម្រាប់កុមារនៅទូទាំងប្រទេសកម្ពុជា។ ផលប៉ះពាល់នៃវិបត្តិនេះ គឺបានធ្វើឲ្យគ្រួសារជាច្រើនបាត់បង់ការងារភ្លាមៗ ធ្វើឲ្យពួកគេពុំមានលទ្ធភាពក្នុងការចំណាយសម្រាប់តម្រូវការមូលដ្ឋានរបស់ពួកគេ ដូចជា ចំណីអាហារ ទឹក ឱសថ តំហែទាំសុខភាព និងការអប់រំដោយសារតែការធ្លាក់ចុះសេដ្ឋកិច្ចបណ្តាលមកពីជម្ងឺកូវីដ១៩នេះ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចាត់នូវវិធានការត្រឹមត្រូវក្នុងការទប់ស្កាត់វិបត្តិនេះដូចជា ផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មកររោងចក្រ ការកាត់បន្ថយពន្ធ និងផ្តល់ការសម្របសម្រួលផ្នែកឥណទានសម្រាប់អាជីវកម្មនានា។ រាជរដ្ឋាភិបាលក៏បានបង្កើតនូវចន្លោះសារពើពន្ធដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចពីវិបត្តិនេះជាពិសេសទៅលើប្រជាជនដែលងាយរងគ្រោះបំផុត។ ទោះបីជាជម្ងឺរាតត្បាត(Covid-19) ធ្វើឲ្យប៉ះពាល់ដល់ឧស្សាហកម្មសំខាន់ៗក៏ដោយ ក៏វិស័យហិរញ្ញវត្ថុ និងកសិកម្មរបស់ប្រទេសកម្ពុជានៅតែមានកំណើនប្រកបដោយចីរភាព ដោយឡែកចំពោះវិស័យទេសចរណ៍ វិស័យកាត់ដេរ និងស្បែកជើង គឺទទួលរងផលប៉ះពាល់ដោយសារជម្ងឺកូវីដ១៩ នេះ។

ក្នុងអំឡុងពេលនៃការរីករាតត្បាតនៃជម្ងឺកូវីដ១៩ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ប្រមូលទុនបានចំនួន ១០លានដុល្លារអាមេរិក ពីការលក់សញ្ញាប័ណ្ណសាជីវកម្មក្នុងដំណាក់កាលទី១។ សញ្ញាប័ណ្ណសាជីវកម្មរបស់ធនាគារត្រូវបានចុះបញ្ជីដំបូងរបស់ខ្លួនក្នុងផ្សារមូលបត្រជាផ្លូវការបន្ទាប់ពីទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) លើលទ្ធផលនៃការដាវ និងការបែងចែក កាលពីថ្ងៃទី

១០ ខែមេសា ឆ្នាំ២០២០។ នៅក្នុងត្រីមាសទី៣ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.កបានចុះបញ្ជីសញ្ញាប័ណ្ណសាជីវកម្មដំណាក់កាលទី២របស់ខ្លួនក្នុងផ្សារមូលបត្រកម្ពុជាជាផ្លូវការ បន្ទាប់ពីទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) លើលទ្ធផលនៃការដាវ និងការបែងចែក កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០។ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានធ្វើការប្រមូលទុនចំនួន ៤០ ពាន់លានរៀល (ប្រហែល១០លានដុល្លារអាមេរិក)ដោយជោគជ័យក្នុងដំណាក់កាលទី២ចំពេលនៃការរីករាតត្បាតជម្ងឺកូវីដ១៩។ ក្នុងដំណាក់កាលទី២នេះ ក្រុមវិនិយោគិនបានទិញសញ្ញាប័ណ្ណសាជីវកម្ម ដែលមានការការពារហានិភ័យប្តូរប្រាក់ជាមួយនឹងអត្រាគូប៉ុងប្រចាំឆ្នាំ៦.៥%និងមានរយៈពេល៣ឆ្នាំ។មូលបត្របំណុលសរុប ៤០០.០០០ត្រូវបានធ្វើការជួញដូរក្នុងដំណាក់កាលទី២ ដែលមានតម្លៃ ១០ ម៉ឺនរៀលក្នុងមួយមូលបត្របំណុល។

ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានមើលឃើញពីលទ្ធផលអាជីវកម្មវិជ្ជមានរបស់ខ្លួន និងបន្តកំណើនប្រកបដោយស្ថិរភាពទាក់ទងនឹងបរិមាណ ក៏ដូចជាប្រាក់ចំណេញ និងកំពុងអនុវត្តការវិនិយោគដែលបានគ្រោងទុកទៅលើសាខាថ្មីចំនួន០២បន្ថែមទៀត (សាខាមហាវិថីព្រះសីហនុនិងសាខាជ្រោយចង្វារ)ដែលបានបើកដំណើរការជាផ្លូវការបន្ទាប់ពីទទួលបានអាជ្ញាបណ្ណធ្វើប្រតិបត្តិការធនាគារពីធនាគារជាតិនៃកម្ពុជា។គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២០ កំណើននៃទ្រព្យសកម្មរបស់យើងមានការកើនឡើងប្រហែល ៤.៧% គឺកើនឡើងពី១.០០០ លានដុល្លារអាមេរិក ទៅ ១.០៤៧ លានដុល្លារអាមេរិក, ឥណទានមានការកើន ២.៦% ពីចំនួន ៦៩២ លានដុល្លារអាមេរិក ទៅ ៧១០ លានដុល្លារអាមេរិក, ប្រាក់បញ្ញើមានការកើនឡើង ៦.៨៩% ពី ៧៤០ លានដុល្លារអាមេរិកទៅ ៧៩១ លានដុល្លារអាមេរិក និងមូលធនមានការកើនឡើង ២.០៤% ពី ១៤៧ លានដុល្លារអាមេរិក ទៅ ១៥០ លានដុល្លារអាមេរិក។ នេះគឺជាកំណើននៅក្នុងត្រីមាសទី២ ប្រៀបធៀបជាមួយត្រីមាសទី៣ ឆ្នាំ ២០២០ដែលសមិទ្ធិផលរបស់ពួកយើងនេះគឺជាអត្រាជោគជ័យក្នុងចំណោមដៃគូរប្រកួតប្រជែងហិរញ្ញវត្ថុជាច្រើននៅក្នុងទីផ្សារ។

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា សម្រាប់ការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹសួរិនស៍ ភីអិលស៊ី ទៅលើការណែនាំអតិថិជននូវផលិតផល និងសេវាធានារ៉ាប់រងផ្សេងៗ។

ក្នុងត្រីមាសទី៣ដដែលនេះធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានធ្វើការពង្រីកអាជីវកម្មរបស់ខ្លួនតាមរយៈការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនទ្រូម៉ាន់នី (ខេមបូឌា) លីមីធីត សម្រាប់ការប្រមូលការទូទាត់សងប្រាក់កម្ចី, ការធ្វើកិច្ចសហប្រតិបត្តិការជាមួយ ក្រុមហ៊ុនបច្ចេកវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ BanhJi សម្រាប់ការបង្កើតគំរូដាក់ពិន្ទុឥណទានខ្នាតតូច និងមធ្យម (SMEs Credit Scoring Model), ការដាក់ឲ្យដំណើរការបណ្ណ MasterCard លើម៉ាស៊ីន ATM របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ហើយនិងផលិតផល និងសេវាថ្មី ឬ មានស្រាប់ផ្សេងៗទៀតដែលកំពុងត្រូវបានអភិវឌ្ឍដោយធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ដើម្បីបំពេញតាមតម្រូវការទីផ្សារ។

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិទាំងអស់នៃធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ, បុគ្គលិករបស់យើងទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្តេជ្ញាចិត្ត, អតិថិជនរបស់យើងទាំងអស់សម្រាប់ទំនុកចិត្តរបស់ពួកគេមកលើធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងគណៈកម្មការមូលបត្រកម្ពុជា (SECC) សម្រាប់ដំបូន្មាន និងការគាំទ្រ។

ខ្ញុំ Yim Yong Taick សូមសម្តែងនូវការដឹងគុណចំពោះការខិតខំប្រឹងប្រែង ដោយទទួលបានលទ្ធផលជោគជ័យក្នុងអំឡុងត្រីមាសទី៣ ឆ្នាំ២០២០ និងបន្តឆ្ពោះទៅរកសមិទ្ធផលដ៏ល្អប្រសើរបន្ថែមទៀតក្នុងត្រីមាសទី៤ ឆ្នាំ២០២០។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 1

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 2

**សមាសភាពក្រុមប្រឹក្សាភិបាល** ........ 3

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ........ 4

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ........ 8

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ 8

ខ. លក្ខណៈនៃធុរកិច្ច ........ 9

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ 10

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ........ 12

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ........ 12

ខ. រចនាសម្ព័ន្ធចំណូល ........ 13

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ........ 13

**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ........ 13

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 14

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ 17

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ 18

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ 19

ង. ផលប៉ះពាល់អតិផរណា ........ 19

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ........ 19

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** ........ 20

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | Phnom Penh Commercial Bank Plc. |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម<br>សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/ ៩៩៩ ៥០០ |
| លេខទូរសារ | (+៨៥៥) ២៣ ៩៩៩ ៥៤០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ០៦៩/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០២ មេសា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Shin Chang Moo |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្តើមប្រតិបត្តិការធនាគារនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្តើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំ គឺ Jeonbuk Bank Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.), ក្រុមហ៊ុន Apro Financial Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co., Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co., Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀត យើងក៏មិនភ្លេចនឹងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើង គាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមបំណាច់ខែកញ្ញា ឆ្នាំ២០២០ ទ្រព្យសកម្មសរុបបានកើនឡើងដល់ ១.០៤៧ លានដុល្លារអាមេរិក និងធ្វើការបម្រើអតិថិជនច្រើនជាង ១១៧.000 នាក់ ជាមួយនឹងសាខាចំនួន២៣ទូទាំងប្រទេស (សាខាថ្មីចំនួន០២ បន្ថែម គឺសាខាមហាវិថីព្រះសីហនុ និងសាខាជ្រោយចង្វារ ដែលត្រូវបានបើកដំណើរការក្នុងខែសីហា ឆ្នាំ២០២០ និងម៉ាស៊ីន ATMs ចំនួន៦២ (ម៉ាស៊ីន ATMs ផ្សេងៗទៀតកំពុងត្រូវបានពិចារណានៅទីតាំងសក្តានុពលផ្សេងៗទៀតក្នុងប្រទេសកម្ពុជា)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តធ្វើការផ្តល់ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្តាញឌីជីថល ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ធនាគារ។ ពួកយើងបានដាក់ឲ្យដំណើរការនូវកំណែទម្រង់ថ្មីមួយទៅលើសេវាធនាគារតាមប្រព័ន្ធអ៊ីនធើណែតរបស់ពួកយើងគឺ "smartBiz 1.5" និងការធ្វើឲ្យប្រសើរឡើងនូវសេវាធនាគារចល័ត "Mobile banking 2.0" ដើម្បីឲ្យកាន់តែប្រាកដថា ពួកយើងបានធ្វើការផ្តល់ជូននូវភាពងាយស្រួលបំផុតនិងមានលក្ខណៈ

ទាន់សម័យជូនដល់អតិថិជនរបស់យើង។អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ live chat ក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ លើសពីនេះទៅទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតមជ្ឈមណ្ឌលសហគ្រាសធុនតូច-មធ្យម (SME Center) ជាលើកដំបូងរបស់ខ្លួន ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ សហគ្រាសធុនតូច-មធ្យម នឹងត្រូវទទួលបាននូវសេវាពិគ្រោះយោបល់អាជីវកម្មផងដែរ។ ពួកយើងក៏បានពង្រីកនូវការិយាល័យបរទេស (Foreign Desk) មានដូចជាការិយាល័យកូរ៉េ ជប៉ុន និងចិន ក៏ដូចជា ហ្គោលក្លឹប និងមជ្ឈមណ្ឌល SME ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផល-សេវារបស់ពួកយើងដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ BanhJi សម្រាប់កិច្ចសហការបង្កើតគំរូដាក់ពិន្ទុឥណទានខ្នាតតូច និងមធ្យម (SMEs Credit Scoring Model)។

នៅក្នុងខែកញ្ញា ឆ្នាំ២០២០ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានធ្វើការប្រមូលទុនចំនួន ៤០ ពាន់លានរៀល (ប្រហែល ១០ លានដុល្លារអាមេរិក) ដោយជោគជ័យក្នុងដំណាក់កាលទី២ ចំពេលនៃការរីករាតត្បាតជម្ងឺកូវីដ១៩។ ក្នុងដំណាក់កាលទី២នេះ ក្រុមវិនិយោគិនបានទិញសញ្ញាប័ណ្ណសាជីវកម្មដែលមានការការពារហានិភ័យប្តូរប្រាក់ ជាមួយនឹងអត្រាគូប៉ុងប្រចាំឆ្នាំ៦.៥% និងមានរយៈពេល៣ឆ្នាំ។ មូលបត្របំណុលសរុប ៤០០.០០០ ត្រូវបានធ្វើការជួញដូរក្នុងដំណាក់កាលទី២ ដែលមានតម្លៃ ១០ម៉ឺនរៀល ក្នុងមួយមូលបត្របំណុល។

នៅត្រីមាសទី៣ ឆ្នាំ ២០២០ ដើម្បីសម្រួលដល់ការសងប្រាក់កម្ចីដល់អតិថិជនរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក យើងបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា(MOU) ជាមួយក្រុមហ៊ុនទ្រូម៉ាន់នី (ខេមបូឌា) លីមីធីត សម្រាប់ការប្រើប្រាស់ Wallet របស់ក្រុមហ៊ុនទ្រូម៉ាន់នី និងភ្នាក់ងារដើម្បីប្រមូលប្រាក់កម្ចី។ ដូច្នេះអតិថិជននឹងអាចបង់ប្រាក់កម្ចីរបស់ពួកគេមក ធនាគារ ភ្នំពេញ ពាណិជ្ជម.ក

តាមរយៈភ្នាក់ងារ និង Wallet របស់ក្រុមហ៊ុនទូរស័ព្ទម៉ាន់នី។ ដើម្បីអបអរភាពជាដៃគូនេះ អតិថិជននឹងរីករាយជាមួយនឹងការមិនគិតថ្លៃសេវារយៈពេល ៣ខែ លើការបង់ប្រាក់កម្ចីដែលចាប់ផ្ដើមពីថ្ងៃទី២៣ ខែកញ្ញា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ អតិថិជននឹងអាចធ្វើការទូទាត់សងតាមរយៈ Wallet របស់ក្រុមហ៊ុនទូរស័ព្ទម៉ាន់នី ឬ ដោយផ្ទាល់នៅតាមភ្នាក់ងារច្រើនជាង ១០,០០០ កន្លែង នៅទូទាំងប្រទេស។

នៅក្នុងខែសីហា ឆ្នាំ២០២០ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបើកសាខាថ្មីជាផ្លូវការចំនួន ២គឺ សាខាមហាវិថីព្រះសីហនុ និងសាខាជ្រោយចង្វារ ដែលបានត្រៀមខ្លួនជាស្រេច ដើម្បីបម្រើអតិថិជនស្ថិតនៅទីតាំងដែលមានភាពងាយស្រួល ដែលសាខាមហាវិថីព្រះសីហនុ មានទីតាំងស្ថិតនៅផ្ទះលេខ ១១៤អឺ០ និង ១១៦អឺ០ មហាវិថីព្រះសីហនុ ភូមិភូមិ៥ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ និងសាខាជ្រោយចង្វារដែលមានទីតាំងនៅផ្ទះលេខ ៥៣៤ស ផ្លូវជាតិលេខ៦ ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ អតិថិជនអាចរីករាយជាមួយសេវាធនាគារនៅថ្ងៃធ្វើការចាប់ពីម៉ោង ៨ព្រឹក ដល់ ម៉ោង ៨យប់ និងនៅថ្ងៃសៅរ៍ ចាប់ពីម៉ោង ៨ព្រឹក ដល់ ៤ល្ងាច ដើម្បីផ្ដល់ភាពងាយស្រួលដល់អតិថិជនជាច្រើនដែលមានភាពមមាញឹកនៅក្នុងរាជធានី។ ទីតាំងនេះមាន Gold Club ដែលអតិថិជន VIP ទាំងអស់នឹងទទួលបានសេវាដែលមានភាពងាយស្រួលជាមួយបុគ្គលិកដែលមានទេពកោសល្យរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ សាខាជ្រោយចង្វារ ស្ថិតនៅលើផ្លូវជាតិលេខ ៦អា គឺជាទីតាំងយុទ្ធសាស្ត្រដែលអាចបម្រើសេវាជូនដល់អតិថិជននៅតំបន់ជ្រោយចង្វារ និងឫស្សីកែវ ដែលសម្បូរទៅដោយអាជីវកម្មខ្នាតតូច និងមធ្យមជាច្រើន។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ សាខាជ្រោយចង្វារ ដែលទើបនឹងបើកថ្មីបានដាក់ដំណើរការជាមួយនឹង មជ្ឈមណ្ឌលអាជីវកម្មខ្នាតតូច និងមធ្យម (SME Center) ជាមជ្ឈមណ្ឌលធនាគារអាជីវកម្មដែលមានគោលដៅចម្បងក្នុងការជួយម្ចាស់អាជីវកម្ម សម្រាប់ផ្ដល់ការពិគ្រោះយោបល់លើផែនការប្រាក់កម្ចី ដើម្បីឱ្យសមនឹងគំរូអាជីវកម្មរបស់ពួកគេ។

ដើម្បីលើកកម្ពស់សេវា ATM របស់ខ្លួនឲ្យកាន់តែប្រសើរឡើង និងអាចទទួលយកនូវបណ្ណ MasterCard ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ដំណើរការសេវាទទួលយកបណ្ណ MasterCard នៅតាមម៉ាស៊ីន ATM របស់ខ្លួនជាផ្លូវការនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០។

ដូចនេះអតិថិជនដែលប្រើប្រាស់បណ្ណ MasterCard ទាំងអស់ អាចធ្វើប្រតិបត្តិការបណ្ណ MasterCard របស់ខ្លួននៅលើម៉ាស៊ីន ATM ទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០២០ ទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា សម្រាប់ការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍ ភីអិលស៊ី ទៅលើការណែនាំអតិថិជននូវផលិតផល និងសេវាធានារ៉ាប់រងផ្សេងៗ។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី៣ ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៦,៥២៥ | ៥,៥៧១ |
| ឥណទានដុលសរុប (លានរៀល) | ២,៨៩៨,៩០១ | ២,៦៤៧,៨១៩ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៤៤,៨៣១ | ១៣៤,៧៥០ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ៣,២៩២,៨៦៤ | ២,៨៩៥,១១៧ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២១ |
| ចំនួនបុគ្គលិកសរុប | ៥០១ | ៤៤៧ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៧០ | ៤៣ |
| ចំនួនម៉ាស៊ីនទូទាត់ | ២៦៦ | ១៧១ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ២០២០ | | ត្រីមាសទី៣ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧១,៣៦៧ | ៩៥.៤៣ | ៦០,៨៦១ | ៩៥.៨៧ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣,៣២៤ | ៤.៤៤ | ២,៥៩២ | ៤.០៨ |
| ៣ | ចំណូលផ្សេងៗ | ៩៤ | ០.១៣ | ២៩ | ០.០៥ |
| ចំណូលសរុប | | ៧៤,៧៨៤ | ១០០ | ៦៣,៤៨១ | ១០០ |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារភ្នំពេញពាណិជ្ជ ម.ក (PPCBank)និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co.,Ltd គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍

ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជ ម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារ និងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់ លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ២០២០ | | ត្រីមាសទី៣ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧១,៣៦៧ | ៩៥.៤៣ | ៦០,៨៦១ | ៩៥.៨៧ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣,៣២៤ | ៤.៤៤ | ២,៥៩២ | ៤.០៨ |
| ៣ | ចំណូលផ្សេងៗ | ៩៤ | ០.១៣ | ២៩ | ០.០៥ |
| **ចំណូលសរុប** | | **៧៤,៧៨៤** | **១០០** | **៦៣,៤៨១** | **១០០** |

ធនាគារភ្នំពេញពាណិជ្ជទទួលបានចំណូលដ៏ធំមកពីការប្រាក់ដែលមាន ៩៥%នៃប្រាក់ចំណូលសរុបក្នុងត្រីមាសទី៣ឆ្នាំ២០២០។

### ៣. ការវិភាគគម្លាតចំណេញដុល

របាយការណ៍លទ្ធផលរួមរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ត្រូវបានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុលទេ ទម្រង់របាយការណ៍នេះបង្ហាញលើចំណេញការប្រាក់សុទ្ធ

ដែលទទួលបានមកពីចំណូលការប្រាក់សរុប ដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកបង្ហាញនិងពិភាក្សានៅក្នុងចំណុចបន្ទាប់លើការវិភាគចំណេញ(ខាត)មុនបង់ពន្ធដូចខាងក្រោម។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៍ចំនេញខាត | ត្រីមាសទី៣ ឆ្នាំ២០២០ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០១៩ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៧១,៣៦៧ | ៦០,៨៦១ | ១០,៥០៦ | ១៧.២៦ |
| ចំណាយលើការប្រាក់ | (៣០,៧៤៩) | (២១,៧១៥) | (៩,០៣៣) | ៤១.៦០ |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៤០,៦១៨** | **៣៩,១៤៥** | **១,៤៧៣** | **៣.៧៦** |
| ចំណូលកម្រៃ និងជើងសារ | ៣,៣២៤ | ២,៥៩២ | ៧៣២ | ២៨.២៤ |
| ចំណាយកម្រៃ និងជើងសារ | (៨៦២) | (៦០៦) | (២៥៧) | ៤២.៣៩ |
| **ចំណូលកម្រៃ និងជើងសារសុទ្ធ** | **២,៤៦១** | **១,៩៨៦** | **៤៧៥** | **២៣.៩២** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ៩៤ | ២៩ | ៦៦ | ២២៩.៤៥ |
| ចំណាយបុគ្គលិក | (៧,៨៥៣) | (៧,២០៤) | (៦៤៩) | ៩.០១ |
| ចំណាយប្រតិបត្តិការ | (៧,២០៣) | (៨,៣៥៤) | ១,១៥១ | (១៣.៧៧) |
| ចំណាយរំលស់ | (៧,៤៥៩) | (៥,៨០៣) | (១,៦៥៦) | ២៨.៥៤ |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **២០,៦៥៧** | **១៩,៧៩៩** | **៨៥៨** | **៤.៣៤** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៏ហិរញ្ញវត្ថុ | ៦៦០ | ២២២ | ៤៣៨ | ១៩៧.៦៥ |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **២១,៣១៨** | **២០,០២១** | **១,២៩៧** | **៦.៤៨** |

ក្នុងត្រីមាសទី៣ឆ្នាំ២០២០ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន២១.៣១៨លានរៀល(៦,៥%កើនឡើងប្រៀបធៀបទៅនឹងត្រីមាសទី៣ឆ្នាំ២០១៩)។ការកើនឡើងនៃប្រាក់ចំណេញភាគច្រើនគឺមកពីការកើនឡើងនៃចំណូលការប្រាក់សុទ្ធដូចជាការប្រាក់បានមកពីកម្ចីរបស់អតិថិជននិងការប្រាក់បានមកពីការដាក់ប្រាក់បញ្ញើនៅធនាគារផ្សេង។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៏ចំណេញខាត | ត្រីមាសទី៣ ឆ្នាំ២០២០ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០១៩ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ២១,៣១៨ | ២០,០២១ | ១,២៩៧ | ៦.៤៨ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៤,៤៤២) | (៥,០៧១) | ៦២៨ | (១២.៣៩) |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **១៦,៨៧៥** | **១៤,៩៥០** | **១,៩២៥** | **១២.៨៨** |

ក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ១៦.៨៧៥លានរៀល ដែលបានកើនឡើង ១៣%ប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០១៩ ដែលបណ្តាលមកពីការកើនឡើងនៃចំណូលការប្រាក់សុទ្ធដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ) និង ការថយចុះចំណាយពន្ធលើប្រាក់ចំណូល។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៏ចំណេញខាត | ត្រីមាសទី៣ ឆ្នាំ២០២០ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០១៩ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ១៦,៨៧៥ | ១៤,៩៥០ | ១,៩២៥ | ១២.៨៨ |
| ការខាតលម្អិតផ្សេងៗ | ៤៨០ | ១,៥០៥ | (១,០២៥) | (៦៨.១២) |
| **ប្រាក់ចំណេញលម្អិតសរុប** | **១៧,៣៥៥** | **១៦,៤៥៥** | **៩០០** | **៥.៤៧** |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ការរាតត្បាតនៃមេរោគឆ្លងវីរុស(COVID-១៩) បានរាលដាលដល់ប្រទេសកម្ពុជាចាប់តាំងពីចុងខែមករា ឆ្នាំ២០២០ ។ ចាប់តាំងពីពេលនោះមកប្រទេសកម្ពុជាក៏កំពុងប្រឈមនឹងការឆ្លងរាលដាលនិងប៉ះពាល់ដល់និរន្តភាពបន្ថែមទៀត ដែលបង្កឱ្យមានការរំខានដល់សកម្មភាពអាជីវកម្មនិងសេដ្ឋកិច្ចជាតិ ។ ទោះយ៉ាងណាគណៈគ្រប់គ្រងរំពឹងថាសកម្មភាពអាជីវកម្មក្រុមនិងធនាគារអាចមានភាពយឺតយ៉ាវបន្តិចក្នុងរយៈពេលដ៏ខ្លីនេះប៉ុន្តែនឹងមិននាំឱ្យមានបញ្ហាគួរឱ្យព្រួយបារម្ភនោះទេដោយសារទំហំប្រតិបត្តិការ

កម្រិតប្រាក់ចំណេញបច្ចុប្បន្ន និងលំហូរសាច់ប្រាក់របស់ក្រុមនិងធនាគារនៅតែរឹងមាំនិងធានាបាននូវនិរន្តភាព។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ផលប៉ះពាល់ពីជំងឺរាតត្បាតឆ្លងមេរោគថ្មី (COVID-១៩) បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើឧស្សាហកម្មស្ទើរតែទាំងអស់រួមទាំងស្ថាប័នធនាគារនិងហិរញ្ញវត្ថុផងដែរ ដែលធ្វើឲ្យតម្រូវការ និងការផ្គត់ផ្គង់ស្ទើរគ្រប់វិស័យការមានការធ្លាក់ចុះ។ ដូច្នេះធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នូវតែចាត់ទុកការរក្សាមូលនិធិដែលមានស្រាប់ និងការទទួលបាននូវមូលនិធិថ្មីដែលមានថ្លៃដើមទាប រួមទាំងការបង្កើនផលិតផលប្រាក់កម្ចីដើម្បីឆ្លើយតបនឹងតម្រូវការលើទីផ្សារ ជាពិសេសប្រាក់កម្ចីសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យមជាកត្តាចំបងបំផុតសម្រាប់ផែនការ និងប្រាក់ចំណេញរបស់ធនាគារ។ ដើម្បីទទួលបាននូវលទ្ធផលទាំងនេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បន្តអភិវឌ្ឍជាបន្តបន្ទាប់នៃប្រព័ន្ធឌីជីថលរបស់ខ្លួន និងបង្កើតភាពសហការជាដៃគូរ ដើម្បីផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត ដែលជាលទ្ធផល ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ BanhJi សម្រាប់កិច្ចសហការបង្កើតគំរូដាក់ពិន្ទុឥណទានខ្នាតតូច និងមធ្យម (SMEs Credit Scoring Model)។ ធនាគារបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា(MOU) ជាមួយក្រុមហ៊ុន ទ្រូម៉ាន់នី (ខេមបូឌា) លីមីធីត សម្រាប់ការប្រើប្រាស់ Wallet របស់ក្រុមហ៊ុនទ្រូម៉ាន់នី និងភ្នាក់ងារ ដើម្បីប្រមូលប្រាក់កម្ចីដើម្បីសម្រួលដល់ការសងប្រាក់កម្ចីដល់អតិថិជនរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ ដើម្បីលើកកម្ពស់សេវា ATM របស់ខ្លួនឲ្យកាន់តែប្រសើរឡើង និងអាចទទួលយកនូវបណ្ណ MasterCard ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ដំណើរការនូវសេវាទទួលយកបណ្ណ MasterCard នៅតាមម៉ាស៊ីន ATM ទាំងអស់របស់ធនាគារ ជាមួយគ្នានេះដែរក៏ទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជាសម្រាប់ការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍ ភីអិលស៊ី ទៅលើការណែនាំអតិថិជននូវផលិតផល និងសេវាធានារ៉ាប់រងផ្សេងៗ ដើម្បីធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ធនាគារ។

លើសពីនេះធនាគារក៏បានវិនិយោគយ៉ាងសំខាន់ផងដែរក្នុងការកែលំអគ្រឹះស្ថានធនាគារដោយខ្លួនឯង ដោយនៅក្នុងខែសីហា ឆ្នាំ២០២០ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបើកសាខាថ្មីជាផ្លូវការចំនួន ២គឺ សាខាមហាវិថីព្រះសីហនុ និងសាខាជ្រោយចង្វារ បន្តតំឡើងបន្ថែម ម៉ាស៊ីនអេធីអឹម ម៉ាស៊ីន Pos និងពង្រីកបណ្តាញទូទាត់អេឡិចត្រូនិកឲ្យកាន់តែទូលំទូលាយជាងមុនបន្ថែមទៀត។

**២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម**

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

**៣. ការវិភាគលើពន្ធ**

ធនាគារភ្នំពេញពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

ការបង់ពន្ធជូនទៅអគ្គនាយដ្ឋានពន្ធដារគឺជាការរួមចំណែកយ៉ាងសំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០ ជាមួយនឹងកាតព្វកិច្ចពន្ធ ធនាគារភ្នំពេញពាណិជ្ជ ម.ក បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "មាស" ពីអគ្គនាយដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២០ និង២០២១។

**៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

ទន្ទឹមនឹងការរីករាលដាលនៃវីរុស(COVID-១៩)មកលើសេដ្ឋកិច្ចពិភពលោក ដែលធ្វើឲ្យមានការធ្លាក់ចុះគួរឲ្យកត់សំគាល់ អាចមានផលប៉ះពាល់ខ្លះដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ធនាគារភ្នំពេញពាណិជ្ជ មានការកើនឡើងបន្តិចនៃចំណូល ដែលមានចំណូលការប្រាក់សុទ្ធសរុប៤០.៦១៨លានរៀលដែលស្មើនឹងការកើនឡើង៣,៨%ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៩។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានអនុវត្តមិនរក្សាទុកនូវស្ថានភាពរូបិយប័ណ្ណបរទេសចំហរច្រើន។ ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញត្តិ ដើម្បីធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួន សម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២០ មិនមានផលប៉ះពាល់ជាសារវន្តនៃអតិផរណាមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

កត្តាជំរុញកំណើនសេដ្ឋកិច្ចដ៏សំខាន់សម្រាប់ប្រទេសកម្ពុជាគឺ វិស័យសំណង់ ទេសចរណ៍ និង ការនាំចេញទំនិញ ដែលនូវតែបន្តរងផលប៉ះពាល់ដោយជំងឺរាតត្បាតនៃវីរុស (COVID-១៩) ។ វីរុស (COVID-១៩) ក៏បានបង្អាក់ការរីកចម្រើននៃវិស័យសំណង់ និងអចលនទ្រព្យដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគបរទេស ហើយគម្រោងអភិវឌ្ឍន៍ធំៗមួយចំនួនក៏ត្រូវបានព្យួរទុក។ ជាមួយនឹងការរឹតត្បិតការធ្វើដំណើរ និងការបិទជាបណ្តោះអាសន្ន ទេសចរណ៍អន្តរជាតិ ការនាំចេញសម្លៀកបំពាក់ សម្ភារៈធ្វើដំណើរ និងផលិតផលស្បែកជើង ក៏បានធ្លាក់ចុះក្នុងកំឡុងពេលនៃជំងឺរាតត្បាតនេះដែរ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិនៃកម្ពុជា (NBC) បានរៀបចំ និងដាក់ចេញនូវទិសដៅយ៉ាងត្រឹមត្រូវសម្រាប់ផែនការជំរុញ និងកាត់បន្ថយផលប៉ះពាល់មកលើសេដ្ឋកិច្ច ក្នុងកំឡុងពេលនៃការរីករាលដាលនៃវីរុស (COVID-១៩) នេះប្រកបដោយប្រសិទ្ធភាព។

រដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តពន្យារពេលអនុវត្តពន្ធលើចំណេញមូលធន ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ទៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ វិញ។ ការពន្យាពេលនេះមានគោលបំណងអនុញ្ញាតឱ្យអ្នកជាប់ពន្ធមានពេលវេលាគ្រប់គ្រាន់ដើម្បីស្វែងយល់កាន់តែច្បាស់ អំពីរបៀបដែលពន្ធលើចំណេញមូលធនត្រូវបានគណនា និងអ្វីដែលត្រូវបានអនុវត្តទាក់ទងនឹងការវិនិយោគ។

យោងតាម ធនាគារជាតិនៃកម្ពុជា ដោយសារតែអត្រាប្តូរប្រាក់រវាងប្រាក់រៀល និងដុល្លារអាមេរិក បានធ្លាក់ចុះពីនិន្នាការនាប៉ុន្មានឆ្នាំមុន។ ធនាគារជាតិនៃកម្ពុជា បានសម្រេចចិត្តធ្វើអន្តរាគមន៍ដើម្បីពង្រឹងអំណាចទិញរបស់ប្រាក់រៀល រក្សាស្ថេរភាពតម្លៃ និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការដាក់ឲ្យដេញថ្លៃប្រាក់ដុល្លារ ដោយអនុញ្ញាត្តិឱ្យធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ដែលមានអាជ្ញាប័ណ្ណ ចូលរួមក្នុងការដេញថ្លៃប្រាក់ដុល្លារអាមេរិកតាមការគ្រោងទុករបស់ធនាគារជាតិនៃកម្ពុជា។ ការផ្លាស់ប្តូរនេះមានគោលបំណងធ្វើឱ្យរូបិយវត្ថុក្នុងស្រុកមានស្ថេរភាព និងរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។

ជាមួយនឹងលទ្ធផលសម្រេចបានរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងត្រីមាសទី៣នេះ គណៈគ្រប់គ្រងបានយល់ឃើញថា ស្ថានភាពបច្ចុប្បន្នមិនមានផលប៉ះពាល់ជាសារវន្ត មកលើលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារទេ។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០

បានអាន និងឯកភាព

លោក YIM, Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank